# សំណួរដែលគេឧស្សាហ៍សួរ (FAQ)

## តើធ្វើដូចម្តេចដើម្បីឲ្យខ្ញុំដឹងអំពីលក្ខណៈវិនិច្ឆ័យនៃការទទួលសិស្សសម្រាប់វិទ្យាល័យទទួលសិស្ស ទូទាំងក្រុង ដែលមានលក្ខណៈសម្បត្តិពិសេស និងវិទ្យាល័យក្នុងតំបន់?

លក្ខណៈវិនិច្ឆ័យនៃការទទួល សិស្សទូទាំងក្រុង និងសិស្សដែលមានលក្ខណៈសម្បត្តិពិសេស អាចឃើញមាននៅក្នុងបញ្ជីឈ្មោះវិទ្យាល័យ។ លោកអ្នកអាចយកបញ្ជីឈ្មោះវិទ្យាល័យតាមអ៊ិនធឺរណិតរបស់ ការិយាល័យចុះឈ្មោះ និងចាត់តាំងសិស្ស តាមរយៈអាស័យដ្ឋាន http://webgui.phila.k12.pa.us/offices/s/student-placement ហើយចុចលើ **Forms**។ លោកអ្នកក៏អាចសួរអ្នកផ្តល់ឱវាទនៅសាលាបានដែរ។

## តើខ្ញុំអាចរកបញ្ជីឈ្មោះវិទ្យាល័យដែលមានកម្មវិធី AS, ES, LSS នៅទីណា? (សម្រាប់ការអប់រំពិសេស តែប៉ុណ្ណោះ)

ការស្នើសុំបញ្ជីឈ្មោះវិទ្យាល័យដែលមានកម្មវិធី (AS, ES, LSS ។ល។) ផ្ទុយនឹងអនុក្រឹត្យនៃកិច្ចព្រមព្រៀងរបស់កម្មវិធី LeGare។ សាលា**ទាំងអស់**របស់យើង គាំទ្រដល់សិស្សានុសិស្សដែលពិការ **ឬ** មានកម្មវិធីសម្រាប់សិស្សានុសិស្សដែលពិការ។

## តើខ្ញុំអាចជួយកូនរបស់ខ្ញុំ ក្នុងការដាក់ពាក្យសុំចូលរៀនរបស់ពួកគេដោយវិធីណា?

មាតាបិតាត្រូវ៖ ១) នាំកូនទៅចូលរួមក្នុងពិព័រណ៌វិទ្យាល័យ ២) ជ្រើសរើសវិទ្យាល័យទៅតាម សមត្ថភាព និងចំណាប់អារម្មណ៍ ៣) សុំលិខិតគាំទ្រពីក្រៅ ៤) សហការជាមួយកូនក្នុងការសរសេរអត្ថបទខ្លីៗ ៥) ប្រគល់ឯកសារសម្រាប់លិខិតដាក់ពាក្យស្នើសុំ**ទាំងអស់** ទៅអ្នកផ្តល់ឱវាទនៅសាលា ឲ្យទាន់ពេល ៦) សហការជាមួយអ្នកផ្តល់ឱវាទក្នុងការណាត់ជួបធ្វើសម្ភាសន៍ និងការសម្តែងសាកល្បង ៧) នាំកូនទៅធ្វើសម្ភាសន៍ និងការសម្តែងសាកល្បង ឲ្យទាន់ពេលវេលា។

## តើខ្ញុំអាចសុំឲ្យមានការលើកលែងសម្រាប់លក្ខណៈវិនិច្ឆ័យនៃការទទួលសិស្សអ្វីមួយ ដោយវិធីណា?

គេអាចផ្តល់ការលើកលែងអ្វីមួយ សម្រាប់លក្ខណៈវិនិច្ឆ័យនៃការទទួលសិស្ស បើសិនជាមានភស្តុតាងអំពីកាលៈទេសៈដែលត្រូវលើកលែង (ដូចជា៖ អវត្តមានដោយសារត្រូវគេងពេទ្យ)។

## តើខ្ញុំត្រូវធ្វើដូចម្តេច ដើម្បីឲ្យដឹងថាគេទទួលកូនខ្ញុំឲ្យរៀននៅវិទ្យាល័យទទួលសិស្ស ទូទាំងក្រុង ដែលមានលក្ខណៈសម្បត្តិពិសេស ឬកម្មវិធី CTE?

គេនឹងផ្ញើលិខិតអំពីការសម្រេចចិត្តទៅផ្ទះ នៅក្នុងលិខិតនោះនឹងមានបញ្ជាក់ថា ទទួល ឬមិនទទួល។ ការសម្រេចចិត្តថាមិនទទួល នឹងបញ្ជាក់ពីមូលហេតុនៅក្នុងលិខិតនោះ។

## តើការពិនិត្យឡើងវិញដោយមិនលម្អៀងជាអ្វី? តើខ្ញុំត្រូវធ្វើដូចម្តេច ដើម្បីឲ្យដឹងថាកូនខ្ញុំមានសិទ្ធិសម្រាប់ ការពិនិត្យឡើងវិញដោយមិនលម្អៀង?

ការពិនិត្យឡើងវិញដោយមិនលម្អៀង គឺជាការពិនិត្យឡើងវិញចុងក្រោយបង្អស់សម្រាប់សិស្សដែលមាន IEP's, 504 Plans និង សិស្ស ELL ដែលបានដាក់ពាក្យសុំចូលក្នុងកម្មវិធី**ដែលយោងទៅលើលក្ខណៈវិនិច្ឆ័យ** (វិទ្យាល័យ ដែល ទទួលសិស្សទូទាំងក្រុង និង ទទួលសិស្សដែលមានលក្ខណៈសម្បត្តិពិសេស) ហើយពួកគេមិនត្រូវបានគេទទួលឲ្យចូលរៀននៅសាលាទាំងនោះ។ ការពិនិត្យឡើងវិញដោយមិនលម្អៀង **មិនពាក់ព័ន្ធ** នឹង វិទ្យាល័យក្នុងតំបន់ (លើកលែងតែសិស្សដាក់ពាក្យសុំចូលក្នុងកម្មវិធី CTE នៅវិទ្យាល័យក្នុងតំបន់) សាលាឆាធ័រ ឬ សាលាដែលមិនមែនជាសាលារបស់ក្រសួង នោះទេ។ សិស្សានុសិស្សដែលមានសិទ្ធិ នឹងទទួលលិខិតណែនាំ អំពីវិធីស្នើសុំ ការពិនិត្យឡើងវិញដោយមិនលម្អៀង។